**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៩ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨**

**រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

**នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ឧបត្ថម្ភដោយ៖ ថវិកាជាតិ**

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៩ សម្រាប់ឆ្នាំ២០១៨ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញស្តីពីគម្រោងបង្ការមេរោគអេដស៍នៅភូមិភាគឧត្តរ បង្ហាញជូនដោយអង្គការ RHAC

-និងបញ្ហាផ្សេងៗ

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។





<u>ប្រធានបទទី១</u>: **លោកវេជ្ជបណ្ឌិត ឆេព ណារាឌុធ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើសកម្មភាពក្នុងខែតុលា ឆ្នាំ២០១៨ ដូចខាងក្រោម៖

- ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៨ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិសកល បានដឹកនាំគណៈប្រតិភូទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការយុទ្ធសាស្ត្រនៃក្រុមប្រឹក្សាភិបាលមូលនិធិសកល នៅប្រទេសស្វីស។
- ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៨ ចាប់ពីម៉ោង២រសៀល ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិសកល បានដឹកនាំការប្រជុំមណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច តាមវីដេអូខនហ្វឺរិន ដើម្បីត្រៀមលក្ខណៈសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៤០ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវ ក្នុងខែវិច្ឆិកា ខាងមុខ។
- ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមវគ្គផ្សព្វផ្សាយពីបច្ចុប្បន្នភាព និងការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ នៅសាលាហ្វឹកហ្វឺនគីមីសាស្ត្រលង្វែក ខេត្តកំពង់ឆ្នាំង។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានអនុម័ត៖
  - ✓ ប្រធានបទ **"យើងប្តេជ្ញារួមគ្នាបញ្ចប់បញ្ហាអេដស៍នៅឆ្នាំ២០២៥"** សម្រាប់ប្រើប្រាស់ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០១៨ និងក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៨ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២១-២៣ ខែវិច្ឆិកា ឆ្នាំ២០១៨។
  - ✓ កិច្ចប្រជុំពេញអង្គលើកទី២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ ។
  - ✓ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅផែនការសកម្មភាពឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ។
- ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានប្រជុំពិនិត្យមើលសៀវភៅបណ្តុះបណ្តាលស្តីពីការបង្កបរិយាកាសអំណោយផល និងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ ដែលគ្របដណ្តប់៖
  - ✓ និយាមប្រតិបត្តិស្តីពីការបង្កបរិយាកាសអំណោយផលសម្រាប់ការងារអេដស៍

- ✓ និយាមប្រតិបត្តិសម្រាប់ការធ្វើសមាហរណកម្មកម្មវិធីអេដស៍ទៅក្នុងផែនការ CDP/CIP ឃុំ សង្កាត់។
- ✓ កម្មវិធីអំពើហិង្សាទាក់ទងនឹងយេនឌ័រ លើក្រុមប្រឈមមុខខ្ពស់

- ➢ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បាននឹងកំពុងធ្វើការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ និងធ្វើផែនការយុទ្ធសាស្ត្រជាតិលើកទី៥៖
  - ✓ បានរៀបចំប្រជុំក្រុមការងារពិនិត្យមើលលទ្ធផលការពិនិត្យឡើងវិញ NSP IV
  - ✓ ប្រជុំក្រុមការងារពិនិត្យមើលសំណួរសម្រាប់ប្រមូលទិន្នន័យ
  - ✓ ចុះប្រមូលទិន្នន័យនៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប
- ➢ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំសិក្ខាសាលាស្តីពីការយល់ដឹងទូទៅនៃឥទ្ធិពលគ្រឿងញៀន ទៅលើការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្រោមអធិបតីភាពលោកជំទាវ **ឱស្ស ច័ន្ទតារីន**។
- ➢ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសម្របសម្រួលកិច្ចប្រជុំលើកទី២ ស្តីពីការសិក្សាសន្ទស្សន៍នៃការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ (Stigma Index 2:0)។ ការសិក្សានេះនឹងធ្វើនៅខេត្ត រាជធានីចំនួន៦ រួមមាន៖ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកណ្តាល និងរាជធានីភ្នំពេញ ដែលមានសំណាកចំនួន១២០០នាក់។

**<u>ផែនការសកម្មភាព និងទិសដៅសម្រាប់អនុវត្តបន្ត</u>**

- ➢ រៀបចំកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅផែនការសកម្មភាពឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅថ្ងៃទី៤ និងថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។
- ➢ រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៨ និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៨។
- ➢ រៀបចំកិច្ចសិក្ខាសាលាពិគ្រោះយោបល់ពីរបកគំហើញ ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍លើកទី៤ និងអនុសាសន៍សម្រាប់ផែនការយុទ្ធសាស្ត្រជាតិលើកទី៥ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានអនុវត្តកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

- **តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម៖** បានរៀបចំប្រជុំផ្សព្វផ្សាយស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ ដោយមានការចូលរួមពីមន្ត្រីរាជការចំណុះឱ្យអគ្គនាយកដ្ឋាន ចំនួន១២៥នាក់ នៅទីស្តីការក្រសួង។
- **តំណាងក្រសួងបរិស្ថាន៖** នឹងចូលរួមសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីផ្សព្វផ្សាយពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ដល់មន្ត្រីបរិស្ថានជាពិសេសសដល់ឧទ្យានុរក្សដែលមានចំនួនជាង១៤០០នាក់។
- **តំណាងក្រសួងមហាផ្ទៃ៖** សំណូមពរឱ្យក្រុមការងារបង្កើតជាក្រុម Telegram ដើម្បីងាយស្រួលក្នុងការទំនាក់ទំនង និងផ្ញើរបាយការណ៍បានទាន់ពេលវេលា។






<u>**ប្រធានបទទី២**</u>: បទបង្ហាញស្តីពីគម្រោងបង្ការមេរោគអេដស៍នៅភូមិភាគឧត្តរ របស់អង្គការ RHAC ដោយលោកស្រី **ប្រាជ្ញ ស៊ីណាត៖**

គោលបំណងគម្រោង គឺផ្តោតទៅលើ៖

- ការស្វែងរកករណីវិជ្ជមានថ្មីក្នុងចំណោម FEW, MSM &TG តាមរយៈពង្រីកការធ្វើតេស្តរកមេរោគអេដស៍ប្រកបដោយប្រសិទ្ធិភាព និងទៅដល់ក្រុមដែលលាក់ខ្លួន ដែលធ្វើនៅលើខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ ខេត្តរតនគិរី និងខេត្តព្រះវិហារ។

- បន្ថែមលើការកំណត់រក និងធ្វើតេស្តឈាម ការពង្រឹងតាមដានករណីថ្មី ពីការបញ្ជូនទៅប្រព័ន្ធសុខាភិបាលសម្រាប់ការថែទាំ។
- ប្រើការទំនាក់ទំនងតាមបច្ចេកវិទ្យាកំណត់បានច្បាស់លាស់នាពេលអនាគត ដូចជាស្មាមមេដៃ និងប្រព័ន្ធផ្ញើសារចំណោមក្រុមផ្សេង។

លទ្ធផលសកម្មភាពគម្រោង(ខែមេសា ដល់ខែកញ្ញា) ឆ្នាំ២០១៨៖

| No | Output Indicator | Result Apr- Sep, 2018 | | | | Target (Total KP) | % compare to total KP |
|---|---|---|---|---|---|---|---|
| | | FEW | MSM | TG | Total | | |
| A | ចំនួនក្រុមគោលដៅដែលបានចុះបញ្ជី | 10,884 | 8,919 | 1,081 | 20,884 | 19,483 | 107% |
| B | ចំនួនក្រុមគោលដៅដែលបានទទួលការអប់រំ | 10,376 | 8,901 | 1,091 | 20,368 | 19,483 | 105% |
| C1a | ចំនួនក្រុមគោលដៅដែលបានទទួលស្រោមអនាម័យ | 10,271 | 8,897 | 1,091 | 20,259 | 19,483 | 104% |
| C1b | ចំនួនក្រុមគោលដៅដែលបានទទួលទឹករំអិល | 3,548 | 7,020 | 739 | 11,307 | 10,245 | 110% |
| C2 | ចំនួនក្រុមគោលដៅដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍ចុងម្រាមដៃ | 5,662 | 4,552 | 629 | 10,843 | 19,483 | 56% |
| C3 | ចំនួនក្រុមគោលដៅដែលមានលទ្ធផលតេស្តមេរោគអេស៍ប្រតិកម្ម | 30 | 99 | 21 | 150 | 0 | |
| C4 | ចំនួនក្រុមគោលដៅដែលបានធ្វើតេស្តអេដស៍បញ្ជាក់ | 20 | 93 | 21 | 134 | 0 | |
| C5 | ចំនួនក្រុមគោលដៅដែលបានធ្វើតេស្តអេដស៍បញ្ជាក់មានលទ្ធផល (+) | 15 | 87 | 20 | 122 | 0 | |
| | ចំនួនក្រុមគោលដៅដែលបានធ្វើតេស្តអេដស៍បញ្ជាក់មានលទ្ធផល(-) | 5 | 6 | 1 | 12 | 0 | |

| No | Output Indicator | Result Apr- Sep, 2018 | | | | Target (Total KP) | % compare to total KP |
|---|---|---|---|---|---|---|---|
| | | FEW | MSM | TG | Total | | |
| | ចំនួនក្រុមគោលដៅដែលមិនអាចទំនាក់ទំនង ឬបាត់បង់ការតាមដាន (LTFU) | 3 | 0 | 0 | 3 | 0 | |
| C6 | ចំនួនក្រុមគោលដៅដែលបានទទួលសេវា Pre-ART/ART | 14 | 87 | 20 | 121 | 0 | |
| C7 | ចំនួនក្រុមគោលដៅដែលបានធ្វើតេស្តស្វាយចុងម្រាមដៃ | 5,656 | 4,534 | 629 | 10,819 | 19,483 | 56% |
| C8 | ចំនួនក្រុមគោលដៅដែលមានលទ្ធផលតេស្តស្វាយប្រតិកម្ម | 74 | 61 | 24 | 159 | 0 | |
| | ចំនួនក្រុមគោលដៅដែលបានធ្វើតេស្តស្វាយបញ្ជាក់មានលទ្ធផល (+) | 31 | 41 | 9 | 81 | 0 | |
| | ចំនួនក្រុមគោលដៅដែលបានធ្វើតេស្តស្វាយបញ្ជាក់មានលទ្ធផល (-) | 4 | 4 | 4 | 12 | 0 | |
| C9 | ចំនួនក្រុមគោលដៅដែលបានបញ្ជូនទៅព្យាបាលស្វាយ | 34 | 45 | 13 | 92 | 0 | |
| C10 | ចំនួនក្រុមគោលដៅដែលបានបញ្ជូនទៅទទួលសេវាពិនិត្យព្យាបាលជំងឺកាមរោគផ្សេងក្រៅពីជំងឺស្វាយ | 86 | 4 | 27 | 117 | 0 | |

**បញ្ហាជួបប្រទះ៖**

- ក្រុមគោលដៅដែលមានលទ្ធផលតេស្តប្រតិកម្មទាំង EW, MSM មិនទៅធ្វើតេស្តបញ្ជាក់ ដោយហេតុផលខ្លាចមានអ្នកជិតខាង គ្រួសារ ឬសហគមន៍ ដឹងមានការរើសអើង។
- ឥរិយាបថក្រុមគោលដៅដែលមានលទ្ធផលតេស្តប្រតិកម្មរួចហើយ ហាក់ដូចជាមានបំណងគេចវេស ហើយមិនយល់ថាការទៅទទួលការព្យាបាលទាន់ពេលជារឿងចាំបាច់(EW&MSM)។
- ការធ្វើតេស្តបញ្ជាក់លទ្ធផល(-) មានចំនួនច្រើន ប្រមាណ១០% នៃចំនួនតេស្តប្រតិកម្ម។
- បំលាស់ប្តូរ ដោយក្រុមអ្នកសហគមន៍ភាគច្រើន សុំលាឈប់ ចំនួនសរុបប្រហែលជាង១០%។
- កង្វះសម្ភារធ្វើតេស្តឈាមរកមេរោគអេដស៍ និងស្វាយនៅតាមតំបន់អនុវត្តការងារ។
- មិនមានកញ្ចប់ថវិកាដើម្បីទិញសម្ភារសម្រាប់គាំទ្រការធ្វើតេស្តឈាម នៅតាមតំបន់អនុវត្តសកម្មភាព។
- ទីកន្លែងសេវាកម្សាន្តមួយចំនួនបានបិទ ហើយអាចប្រឈមនឹងបិទបន្ថែមទៀត ដែលអាចនឹងបាត់ការទាក់ទងជាមួយក្រុមគោលដៅខ្លះដែរ និងមានខេត្តមួយចំនួនតូច ដែលម្ចាស់សេវាមិនអនុញ្ញាតឱ្យធ្វើការនោះដែរ។

**ដំណោះស្រាយ៖**

- បន្តជួប ផ្តល់ប្រឹក្សា និងស្វែងរកការដំណោះស្រាយពីក្រុមបច្ចេកទេសជួយសម្របសម្រួល។ ពង្រឹងការអនុវត្តការផ្តល់ប្រឹក្សាមុន និងក្រោយការធ្វើតេស្ត។
- ពង្រឹងបច្ចេកទេសអនុវត្តការធ្វើតេស្តឈាមបន្ថែម។
- បន្តជ្រើសរើសថ្មី និងពង្រឹងសមត្ថភាពបន្ថែម
- សហការ និងសុំខ្ចីសម្ភារសម្រាប់ការធ្វើតេស្តឈាមជាបណ្តោះអាសន្នពីមន្ទីរសុខាភិបាលខេត្ត
- អង្គការរ៉ាក់ បានស្នើសុំកញ្ចប់ថវិកាពី NCHADS សម្រាប់ទិញសម្ភារ។ យើងបានទទួលការយល់ព្រមដើម្បីដំណើរការទិញសម្ភារទាំងអស់នោះ។
- ត្រៀមទុកជាមុនជាមួយក្រុមគោលដៅតាមរយៈលេខទូរស័ព្ទ តាមបណ្តាញសង្គម និងប្រព័ន្ធផ្សេងទៀត ក្នុងករណីសេវាកម្សាន្តមួយចំនួនបានបិទ។

**ផែនការបន្ទាប់៖**

- បន្តពង្រឹងសមត្ថភាពបុគ្គលិក និងអ្នកសហគមន៍ អំពីការធ្វើតេស្តឈាមពីការជោះចុងម្រាមដៃ។
- ស្នើសុំជំនួយបច្ចេកទេសពី NCHADS ដើម្បីធ្វើការអភិបាល និងពង្រឹងជំនាញបន្ថែម។
- ដំណើរការបង្កើតប្រព័ន្ធ និងម៉ាស៊ីនស្កេនម្រាមដៃ Finger Print សម្រាប់ការតាមដានក្រុមគោលដៅ និងការពារការកត់ ឬរាប់ស្ទួន។
- នឹងចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រ PDI+ ដែលអាចបង្កើនចំនួនរកឃើញករណីថ្មី
- បង្កើតប្រព័ន្ធផ្ញើសារអប់រំជាអក្សរ តាមទូរស័ព្ទ រួមនឹងបន្តបោះពុម្ពសម្ភារផ្សព្វផ្សាយបន្ថែមទៀត

ជាកិច្ចបន្តឯកឧត្តមប្រធានអង្គប្រជុំ បានមានប្រសាសន៍ជម្រាបជូនអង្គប្រជុំថា ក្នុងរយៈពេលខាងមុខនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នឹងធ្វើយុទ្ធនាការផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០១៨។ ក្នុងយុទ្ធនាការនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នឹងចែកជូនដល់ក្រសួង ស្ថាប័ន នូវបេជាសម្រាប់ចងតាមក្រសួង ស្ថាប័ន សម្រាប់ក្រើនរម្លឹកដល់ប្រជាជនដែលមកចូលរួមឱ្យចេះបង្ការខ្លួនពីមេរោគអេដស៍ ឱ្យស្របទៅនឹងប្រធានបទ **"យើងប្តេជ្ញារួមគ្នាបញ្ចប់បញ្ហាអេដស៍នៅឆ្នាំ២០២៥"**។

បន្ទាប់មក ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបជូនដល់សមាជិក សមាជិកានៃអង្គប្រជុំថា **កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១០ នឹងប្រព្រឹត្តទៅនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨** ។

កិច្ចប្រជុំបានបញ្ចប់ទៅក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**ឧបសម្ពន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃសុក្រ ៩រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ភ្នំពេញ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨

**បានឃើញ និងឯកភាព**
**អគ្គលេខាធិការ**

**វេជ្ជ.តៃង គន្ធី**

**បានពិនិត្យត្រឹមត្រូវ**
ប្រធាននាយកដ្ឋាន
ទាក់ទង និងចលនាប្រភពធនធាន

**អ្នកធ្វើរបាយការណ៍**